រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៩៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ឧបដ្ឋានសាលា នៅវត្តអម្ពរនារាម និងកសាងរបងសាលា បង្គន់អនាម័យ បណ្ណាល័យ ទ្វារបង្អួច ចាក់ដីបំពេញទីធ្លាសាលា នៅសាលាបឋមសិក្សាប្រាំយ៉ាម ស្ថិតក្នុងឃុំស្វាយសាច់ភ្នំ និងឃុំប្រាំយ៉ាម ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិ:

១-	លោក	សុខ	ខួនសេង	សប្បុរសជននៅខេត្តកំពង់ចាម	ថវិកា	១០.០៥០	ដុល្លារ
២-	លោក	ឌុច	ស៊ីថា	សប្បុរសជននៅខេត្តព្រះសីហនុ	ថវិកា	១០.០០០	ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ:

១-	លោក	នុត	លី	សប្បុរសជននៅខេត្តព្រះសីហនុ	ថវិកា	៥.១០០	ដុល្លារ
២-	លោក	ចាន់	សុធារ៉ា	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកា	៥.០០០	ដុល្លារ
៣-	លោក	ជិន	តារីន	សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា	ថវិកា	៥.០០០	ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២០០ . អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន០៦រូប ដែលមានស្នាដៃល្អខិតខំយកចិត្តទុកដាក់ក្នុងការបំពេញភារកិច្ចលើវិស័យអប់រំ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទៈ

១-ឯកឧត្តម	អ៊ុក ថុន	សាកលវិទ្យាធិការ សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ
២-លោក	គីន សំអួន	សាកលវិទ្យាធិការរង សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនៈ

១-លោក	សិត ខន	សាកលវិទ្យាធិការរង សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ
២-លោក	ពិត ច័ន្ទណារ៉ូ	សាកលវិទ្យាធិការរង សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ
៣-លោក	សុក រ៉ាឌី	នាយកប្រតិបត្តិសាខាព្រៃវែង សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ
៤-លោក	យ៉ាន សំបូរ	នាយកប្រតិបត្តិសាខាកំពង់ចាម សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ៨ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧០៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងផ្លូវថ្នល់ ស្ពាន និងអណ្តូងទឹក ស្ថិតនៅក្នុងស្រុកពាមរាំង ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម ៖

១-អ្នកស្រី ម៉ាន់ សារី នាយករងក្រុមហ៊ុន ខូល អិល ធីឌី ថវិកាចំនួន ១០.២៥០ ដុល្លារ ·

២-លោក ជា ដែន នាយករងក្រុមហ៊ុន ខូល អិល ធីឌី ថវិកាចំនួន ១០.២៥០ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ៨ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២០២ . អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈ ជូនសព

- វរសេនីយ៍ទោ **នៃ គង់ហ៊ាន** អត្តលេខ ០០៣២៨៨ នាយរងការិយាល័យ ស្ថាប័នចំណុះ អធិការដ្ឋាន អគ្គបញ្ជាការដ្ឋាន

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៨ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧០៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ផ្តល់ជូនអង្គការ និងសប្បុរសជននៅក្នុង និងក្រៅប្រទេសចំនួន ១១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង អគារសិក្សា០១ខ្នង មាន ០៥បន្ទប់ ស្ថិតនៅក្នុងស្រុកជុំគីរី អគារសិក្សា០១ខ្នង មាន ០៥បន្ទប់ ស្ថិតនៅក្នុងស្រុកឈូក បណ្ណាល័យ០១ខ្នង មានបណ្តោយ ១១ម៉ែត្រ និងទទឹង ០៧ម៉ែត្រ បំពាក់ដោយគ្រឿងសង្ហារឹមគ្រប់គ្រាន់ ស្ថិតនៅក្នុងស្រុកកំពង់ត្រាច ខេត្តកំពត ដែលមានរាយនាមដូចខាងក្រោម :

១-អង្គការ **ស៊ីប៉ា** (**SIPAR**)	នៅប្រទេសបារាំង	ថវិកាចំនួន ១៤.៩៧០ ដុល្លារ
២-លោក **Jean FranÇois CANTON**	សប្បុរសជននៅប្រទេសបារាំង	ថវិកាចំនួន ១៤.០០០ ដុល្លារ
៣-លោកស្រី **Otto de GRAAFF**	សប្បុរសជននៅប្រទេសបារាំង	ថវិកាចំនួន ១៤.០០០ ដុល្លារ
៤-លោក **Arnaud COSSERAT**	សប្បុរសជននៅប្រទេសបារាំង	ថវិកាចំនួន ១៣.០០០ ដុល្លារ
៥-លោក **Vincent STRAUSS**	សប្បុរសជននៅប្រទេសបារាំង	ថវិកាចំនួន ១២.០០០ ដុល្លារ
៦-លោកស្រី **Robert DENEKE**	សប្បុរសជននៅប្រទេសបារាំង	ថវិកាចំនួន ១២.០០០ ដុល្លារ
៧-លោក **Laurent DOBLER**	សប្បុរសជននៅប្រទេសបារាំង	ថវិកាចំនួន ១១.០០០ ដុល្លារ

៨-លោកស្រី **Bernadette CHAVENTON** សប្បុរសជននៅប្រទេសបារាំង ថវិកាចំនួន ១១.០០០ ដុល្លារ

៩-លោកស្រី **Magali PETITMENGIN** សប្បុរសជននៅប្រទេសបារាំង ថវិកាចំនួន ១១.០០០ ដុល្លារ

១០-លោក **លី ម៉ាត** សប្បុរសជនខ្មែររស់នៅប្រទេសបារាំង ថវិកាចំនួន ១១.០០០ ដុល្លារ

១១-លោក **គង់ សាង** សប្បុរសជននៅខេត្តកំពត ថវិកាចំនួន ១០.០០០ ដុល្លារ

មាត្រា ២.–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកំពត និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧០៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ សេនា ជូនអ្នកពិគ្រោះយោបល់ផ្លូវការនិងក្រុមហ៊ុនសាងសង់ ចំនួន០៥រូប ដែលមានស្នាដៃល្អក្នុងការចូលរួមធ្វើសហប្រតិបត្តិការជាមួយក្រសួងពាណិជ្ជកម្ម លើការងារពិព័ណ៌ពិភពលោក ២០១០ សៀងហៃ (The world Exposition Shanghai China 2010) ប្រទេសចិន ដូចមានរាយនាមខាងក្រោម ៖

១-លោក Wong Wai Chin Anthony	អ្នកពិគ្រោះយោបល់ផ្លូវការ
២-លោក Geng Li	ប្រធានក្រុមហ៊ុនសាងសង់ ZH-EXPO SERVICE CO.LTD
៣-លោក Jackie Soe	ក្រុមហ៊ុនសាងសង់ ZH-EXPO SERVICE CO.LTD
៤-លោក Mike Ng	ក្រុមហ៊ុនសាងសង់ ZH-EXPO SERVICE CO.LTD
៥-លោក Gao · Hua	President of the Chinese Chamber·of Commerce in Cambodia President of Transpeed Travel (Holdings) Ltd .

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២០៥ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនសមាជិកគណៈកម្មការអន្តរក្រសួង មន្ត្រីប្រចាំការក្រុមការងារបច្ចេកទេស និងសិប្បករ-សិប្បការិនី ចំនួន១២៩រូប ដែលមានស្នាដៃល្អក្នុងការខិតខំបំពេញភារកិច្ចចូលរួមពិព័រណ៍ពិភពលោក (The world Exposition Shanghai China 2010) ប្រទេសចិន ទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទៈ

១-ឯកឧត្តម អៀវ ស៊ុនលី ប្រធាននាយកដ្ឋានហិរញ្ញកិច្ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាសមាជិកគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំនិងចូលរួមពិព័រណ៍ពិភពលោក និងចូលរួមពិព័រណ៍ពាណិជ្ជកម្ម អន្តរជាតិ

២-លោក ស៊ីន សុថា ប្រធាននាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម និងជាសមាជិកអចិន្ត្រៃយ៍គណៈកម្មការអន្តរក្រសួងដើម្បីរៀបចំនិងចូលរួមពិព័រណ៍ពិភពលោក និងចូលរួមពិព័រណ៍ពាណិជ្ជកម្ម អន្តរជាតិ

៣-លោក ហេង សោភណ្ឌ័ ប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល និងជាសមាជិកគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងចូលរួមពិព័រណ៍ពាណិជ្ជកម្ម អន្តរជាតិ

៤-លោក សុខ ជា អគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងសៀងហៃ

៥-លោក ជា គៀត អនុប្រធាននាយកដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាសមាជិកគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំនិងចូលរួមពិព័រណ៍ពិភពលោក និងចូលរួមពិព័រណ៍ពាណិជ្ជកម្ម អន្តរជាតិ

៦-លោក សុខ ជារិទ្ធិ អនុប្រធាននាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម និងជាសមាជិកគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងចូលរួមពិព័រណ៍ពាណិជ្ជកម្ម អន្តរជាតិ

៧-លោក អ៊ុំ្រាំ ទីរៈ អនុប្រធាននាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម និងជាសមាជិកគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងចូលរួមពិព័រណ៍ពាណិជ្ជកម្ម អន្តរជាតិ

៨-លោក សារុន រ៉ាឌី អនុប្រធាននាយកដ្ឋានអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិកគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងចូលរួមពិព័រណ៍ពាណិជ្ជកម្ម អន្តរជាតិ

៩-លោក គឹម ដារ៉ា ប្រធានការិ. អគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:

១-លោក	សំ	ប៉ូរី	ប្រធានការិយាល័យ នាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
២-លោក	កែប	ទុត្ថា	ប្រធានការិយាល័យ នាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
៣-លោក	ហង្ស	សុវណ្ណ	ប្រធានការិយាល័យ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
៤-លោក	ត្រេន	ទីថុល	អនុប្រធានការិយាល័យ នាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
៥-លោក	អៀ	អឺរិទ្ធី	អនុប្រធានការិយាល័យនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
៦-លោក	ជា	ពុទ្ធារកល្យៈ	អនុប្រធានការិយាល័យនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
៧-លោក	ផេង	ប៉ូច	អនុប្រធានការិយាល័យនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
៨-លោក	ប៉ែន	តារ៉េត	អនុប្រធានការិយាល័យនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
៩-លោក	ម៉ី	ម៉ិនលី	អនុប្រធានការិយាល័យនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
១០-លោកស្រី	ប៊ិន	ចំណាន	អនុប្រធានការិយាល័យនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
១១-លោកស្រី	នួន	ដានិត	អនុប្រធានការិយាល័យនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
១២-លោក	ជា	ស៊ីណាត	មន្ត្រីនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
១៣-លោក	ស៊ាន	សុគា	មន្ត្រីនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
១៤-លោក	ជិន	ឌីណា	មន្ត្រីនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
១៥-លោក	ឧត្តម	ទិជ្ជា	ប្រធានក្រុមជាង
១៦-លោក	គង់	ឆឿង	អនុប្រធានក្រុមជាង
១៧-លោក	ឃួន	ថោងស៊ីន	មន្ត្រី SCA (ផ្នែករូបភាព)
១៨-លោក	អ៊ុក	សុភាព	មន្ត្រីក្រសួងទេសចរណ៍ (ផ្នែករូបភាព)
១៩-កញ្ញា	ហ៊ី	អេឡែន	អ្នកយកព័ត៌មានទូរទស្សន៍ជាតិ
២០-លោក	ឆឿង	ច័ន្ទតារា	អ្នកថតរូបទូរទស្សន៍ជាតិ
២១-លោក	អៀន	សីរីទ្ធ	ធនាគារកាណាឌីយ៉ា
២២-លោក	លន់	គឹមលាង	នាយកក្រុមហ៊ុនឆេងហាក់ត្បូងពេជ្រ
២៣-លោកស្រី	យូ	គីមហៃ	នាយិកាក្រុមហ៊ុន ប៉ៃលិន លក់វត្ថុ អនុស្សាវរីយ៍
២៤-លោក	ទ្រឹម	ភ្លឿន	ក្រុមហ៊ុន Cafeteria
២៥-លោកស្រី	ប៉ែន	សុខហួន	សាស្ត្រាចារ្យសិល្បៈ
២៦-លោកស្រី	ប៉ែន	សុខជា	សាស្ត្រាចារ្យសិល្បៈ
២៧-កញ្ញា	ប្រសិទ្ធ	វិច្ឆិកា	សិល្បការិនី
២៨-កញ្ញា	ប្រសិទ្ធ	ទិវីទី	សិល្បការិនី
២៩-កញ្ញា	រដ្ឋ	ច័ន្ទមុនី	សិល្បការិនី
៣០-លោកស្រី	ហ៊ុល	តឿនណារី	សិល្បការិនី
៣១-កញ្ញា	សំអាត	សុវណ្ណី	សិល្បការិនី
៣២-លោកស្រី	ហង្ស	សុភាព	សិល្បការិនី
៣៣-កញ្ញា	ប៉ុក	សុវណ្ណ	សិល្បការិនី

៣៤-កញ្ញា	ទុះ	ច័ន្ទបូលី	សិល្បការិនី
៣៥-លោកស្រី	អ៊ុក	ផល្លីន	សិល្បការិនី
៣៦-លោក	សៅ	រិទ្ធី	សិល្បករ
៣៧-កញ្ញា	អ៊ូ	ដាលីស	សិល្បការិនី
៣៨-កញ្ញា	ហែម	លីនដា	សិល្បការិនី
៣៩-លោកស្រី	ចិន្ត	ច័ន្ទសុដា	សិល្បការិនី
៤០-លោកស្រី	កុយ	ស៊ីណា	សិល្បការិនី
៤១-លោក	ចាន់	និម្មិត	សិល្បករ
៤២-លោកស្រី	ឡេង	វណ្ណី	សាស្ត្រាចារ្យសិល្បៈ
៤៣-កញ្ញា	ចាប	ចន្ទ្រា	សិល្បការិនី
៤៤-លោកស្រី	និត្យ	ច័ន្ទនិមល	សិល្បការិនី
៤៥-កញ្ញា	កែវ	ពេជ្រចរណៃ	សិល្បការិនី
៤៦-កញ្ញា	ខៀវ	ច័ន្ទតារា	សិល្បការិនី
៤៧-កញ្ញា	ម៉ុក	សារ៉ាម៉ានី	សិល្បការិនី
៤៨-លោក	ចក់	ចំណាន	សិល្បករ
៤៩-លោក	ជុំ	ប្រសើរ	សិល្បករ
៥០-លោក	សោម	សុតារម្យ	សិល្បករ
៥១-លោក	រស់	ដារ៉ារិទ្ធ	សិល្បករ
៥២-លោក	ម៉ុក	សុខុម	សិល្បករ
៥៣-លោក	ឃួន	ចំរើន	សិល្បករ
៥៤-លោក	មាឌ្យ	បូរិន	សិល្បករ
៥៥-លោក	សេង	កាលីវ៉ាន់	សិល្បករ
៥៦-លោក	សេក	សុភា	សិល្បករ
៥៧-លោក	ម៉ម	សុជាតិ	សិល្បករ
៥៨-លោកស្រី	សាន	ថាវរី	សិល្បការិនី
៥៩-កញ្ញា	ខៀវ	ច័ន្ទកញ្ញា	សិល្បការិនី
៦០-កញ្ញា	គាង	ស្រីលាភ	សិល្បការិនី
៦១-លោក	ឡាំ	វីរៈ	សិល្បករ
៦២-លោក	ខៀវ	សុវណ្ណារិទ្ធ	សិល្បករ
៦៣-លោក	យឹម	សារិទ្ធ	សិល្បករ
៦៤-លោក	យ៉ង់	យ៉េង	សិល្បករ
៦៥-កញ្ញា	ម៉ៅ	ញានសុគារុណា	សិល្បការិនី
៦៦-លោក	ស៊ីន	គីមហុង	សិល្បករ
៦៧-លោក	ឌឹម	សាម៉ូឌី	សិល្បករ
៦៨-លោកស្រី	ចាន់	ស៊ីណា	សិល្បការិនី
៦៩-កញ្ញា	ថន	ច័ន្ទគីណា	សិល្បការិនី
៧០-កញ្ញា	ទ័ន	សុវណ្ណបុប្ផា	សិល្បការិនី
៧១-លោកស្រី	ចក់	ផល្លា	សិល្បការិនី
៧២-លោកស្រី	យឹម	គោត្តនី	សិល្បការិនី

៧៣-លោកស្រី	ទី	រតនា	សិល្បការិនី
៧៤-កញ្ញា	រ៉ា	សុវនីតា	សិល្បការិនី
៧៥-លោកស្រី	ស៊ឹម	រ៉ាទី	សិល្បការិនី
៧៦-លោកស្រី	តឿក	សុខេម	សិល្បការិនី
៧៧-លោក	ពេញ	ជំនិត	សិល្បករ
៧៨-លោកស្រី	ឈឹម	ណាលីន	សិល្បការិនី
៧៩-កញ្ញា	គាង	ស្រីខ្មៅន	សិល្បការិនី
៨០-លោកស្រី	ឌីន	សុធ្ធាទីន	សិល្បការិនី
៨១-លោក	សំអាត	សុវណ្ណា	សិល្បករ
៨២-លោក	សេង	សំអ៊ែល	សិល្បករ
៨៣-លោកស្រី	តិប	ឆងផ្កា	សិល្បការិនី
៨៤-កញ្ញា	កែន	លក្ខិណា	សិល្បការិនី
៨៥-កញ្ញា	ម៉ុក	បញ្ញារ័ត្ន	សិល្បការិនី
៨៦-កញ្ញា	ឃួន	សុខហេង	សិល្បការិនី
៨៧-កញ្ញា	ឈឹម	ថាវី	សិល្បការិនី
៨៨-លោកស្រី	តាំង	ចរិយា	សិល្បការិនី
៨៩-កញ្ញា	ម៉េង	ចំនួនឆារ៉ា	សិល្បការិនី
៩០-កញ្ញា	ឌួង	ហង្សវីដា	សិល្បការិនី
៩១-លោកស្រី	ចន	ចំនួនលក្ខិណា	សិល្បការិនី
៩២-លោក	យុត្តារា	ឆានី	សិល្បករ
៩៣-លោក	ស៊ិន	សំនៀង	សិល្បករ
៩៤-លោកស្រី	កែន	ពិសី	សិល្បការិនី
៩៥-លោក	អ៊ុន	សិទ្ធា	សិល្បករ
៩៦-លោក	ប៉ែន	ចំរុង	សិល្បករ
៩៧-កញ្ញា	សារ៉ាយ	សក្ខំណា	សិល្បការិនី
៩៨-កញ្ញា	នឹម	រដ្ឋា	សិល្បការិនី
៩៩-លោក	សាយ	គីមសៀ	សិល្បករ
១០០-លោក	សូរី	សុរដ្ឋា	ជាងចម្លាក់
១០១-លោក	សយ	រតនា	ជាងចម្លាក់
១០២-កញ្ញា	អាន	សុជាតា	តម្បាញ
១០៣-លោក	ម៉ៅ	ប៊ុនធឿន	ក្រុមជាង
១០៤-លោក	ឡុង	ស៊ីទុនថា	ក្រុមជាង
១០៥-លោក	ស៊ឹន	ប៉ាក់	ក្រុមជាង
១០៦-លោក	អ៊ុំ	ដួ	ក្រុមជាង
១០៧-លោក	អ៊ុយថៃ	ឈីនរ៉ាម	ក្រុមជាង
១០៨-លោក	យក់	ចាន់រិទ្ធិ	ក្រុមជាង
១០៩-លោក	អ៊ុំ	ភួឡា	ក្រុមជាង
១១០-កញ្ញា	លី	ចេង	ធនាគារកាណាឌីយ៉ា
១១១-កញ្ញា	ឈាង	សោភា	ធនាគារកាណាឌីយ៉ា

១១២-កញ្ញា	វើង	សាំង	ធនាគារកាណាឌីយ៉ា
១១៣-លោក	ថាន់	លក្ខិណា	អ្នកថតរូបទូរទស្សន៍អាស៊ីអាគ្នេយ៍
១១៤-លោក	ហេង	សុវណ្ណារិទ្ធ	អ្នកយកព័ត៌មានទូរទស្សន៍អាស៊ីអាគ្នេយ៍
១១៥-លោក	លាង	ដីលុច	អ្នកយកព័ត៌មានកាសែតរស្មីកម្ពុជា
១១៦-កញ្ញា	ពួយ	គៀង	អ្នកយកព័ត៌មានកាសែតពាណិជ្ជកម្ម
១១៧-លោក	ចា	សុវណ្ណារិទ្ធ	អ្នកយកព័ត៌មានទូរទស្សន៍បាយ័ន
១១៨-លោក	ហេង	សុភី	អ្នកថតរូបទូរទស្សន៍បាយ័ន
១១៩-លោកស្រី	សាន	ឆេងហាក់	ក្រុមហ៊ុនឆេងហាក់ត្បូងពេជ្រ
១២០-កញ្ញា	កែវ	យូសេង	ក្រុមហ៊ុន ប៉ៃលិន លក់វត្ថុអនុស្សាវរីយ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២០៧ . ទទឌក្រ . ៩៥

អនុក្រឹត្យ

ស្តីពីការជូនមេដាយ សហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ ~

ត្រូវបានបំពាក់មេដាយ **សហមេត្រី ថ្នាក់ធិបឌិន្ទ** ជូនដល់លោក **PHIL HUNTER** នាយនគរបាលសម្របសម្រួលជាន់ខ្ពស់ នគរបាលសហព័ន្ធអូស្ត្រាលី នៃស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា បានជួយឧបត្ថម្ភគាំទ្រក្នុងការផ្លាស់ប្តូរព័ត៌មានសំខាន់ៗជាប្រចាំ និងជួយដល់ការងារបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ ~

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា១ និងមាត្រា២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤១៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនគ្រឿងឥស្សរិយយសស្ពាបនាជាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ឯកឧត្តម ញឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១ ៖ ត្រូវបានបំពាក់គ្រឿងឥស្សរិយយស **ស្ពាបនាជាន** តាមលំដាប់ថ្នាក់ ជូនដល់សប្បុរសជនជាតិចិនចំនួន០២រូប ដែលមានចិត្តសប្បុរស ជួយឧបត្ថម្ភថវិកា ដើម្បីកសាងព្រះវិហារ ដែលស្ថិតនៅវត្តព្រះស្រែ ឃុំតាឡំ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម៖

ក.មេដាយមាសស្ពាបនាជាន៖

១.បណ្ឌិត Ip Pui Lan ប្រធានក្រុមហ៊ុន Emperor Group

ខ.មេដាយសំរិទ្ធស្ពាបនាជាន៖

២.អ្នកស្រីបណ្ឌិត Chan Hei Ling, Helen ប្រធានក្រុមហ៊ុន Vita Green International Inc។

មាត្រា ២ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវអនុវត្តអនុក្រឹត្យនេះឲ្យបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤០....ស.ស.រ

សេចក្តីសំរេច

ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំ រេ ច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១០ នៅសាធារណរដ្ឋប្រជាមានិតចិន រហូតដល់ពេលសម្តេចតេជោនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ២

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.១០-១៩៧ ប្រ.ក.

លិខិតចូល
ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ 2010

ប្រកាស
ស្តីពី
ការគណនាមូលនិធិផ្ទាល់សុទ្ធ របស់ធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងស្មារតីអង្គប្រជុំថ្នាក់ដឹកនាំ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០

សម្រេច

ប្រការ ១.

គ្រឹះស្ថានធនាគារត្រូវគណនាមូលនិធិផ្ទាល់សុទ្ធឲ្យស្របតាមបទប្បញ្ញត្តិនៃប្រកាសនេះ ។ រាល់អនុបាតនិងកម្រិតកំណត់ប្រុងប្រយ័ត្នដែលទាក់ទងនឹងមូលនិធិផ្ទាល់សុទ្ធ ត្រូវគណនាឲ្យស្របតាមវិធាននៃការគណនានេះ។ លើសពីនេះ ដើមទុនឬទាយជ្ជទានដែលបានបង់ត្រូវតែស្មើ ឬលើសពីដើមទុនអប្បបរមា ។

ប្រការ ២.

គ្រឹះស្ថានធនាគារត្រូវបង្កើតគោលនយោបាយ នីតិវិធី និងដំណើរការត្រួតពិនិត្យផ្ទៃក្នុង សំដៅធានាការប្រតិបត្តិតាមជាអចិន្ត្រៃយ៍នូវកាតព្វកិច្ចជាបទបញ្ជាទាំងអស់ ទាក់ទងនឹងអនុបាតសាធនភាពអប្បបរមា និងកម្រិតកំណត់ដែលទាក់ទងនឹងមូលនិធិផ្ទាល់សុទ្ធ។

ប្រការ ៣.

ធនាគារជាតិនៃកម្ពុជា អាចតម្រូវឲ្យគ្រឹះស្ថានធនាគារអនុវត្តនីតិវិធីពិសេស ក្រោមរូបភាពជាការដកចេញនូវខ្ទង់មួយចំនួនថែមទៀតពីការគណនាមូលនិធិផ្ទាល់សុទ្ធ ដោយមិនគិតដល់វិធានទូទៅនៃការគណនាដូចមានចែងនៅក្នុងប្រកាសនេះ ។ ការអនុវត្តនីតិវិធីពិសេសនេះគឺ ដើម្បីស្តារឡើងវិញនូវការប្រតិបត្តិតាមបទបញ្ញា និងដើម្បីឆ្លុះបញ្ចាំងឲ្យឃើញហានិភ័យជាក់ស្តែងនិងហានិភ័យជាសក្តានុពល ក្នុងគោលបំណងប្រុងប្រយ័ត្ន ។

ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការអនុវត្តនីតិវិធីពិសេសនេះ ហើយគ្រឹះស្ថានធនាគារត្រូវអនុវត្តតាមភ្លាម រហូតដល់មានការណែនាំផ្សេងជាលាយលក្ខណ៍អក្សរ។

ប្រការ ៤.

មូលនិធិផ្ទាល់សុទ្ធសរុបមានសមាសធាតុ ២ ដាច់ដោយឡែកពីគ្នាគឺ ៖

- ដើមទុនថ្នាក់ទីមួយ (ដើមទុនស្នូល) និង
- ដើមទុនថ្នាក់ទីពីរ (ដើមទុនបំពេញបន្ថែម)

ដើមទុនថ្នាក់ទីពីរមិនត្រូវលើសពី ១០០% នៃដើមទុនថ្នាក់ទីមួយទេ ឬ មិនត្រូវលើសពី ៥០% នៃមូលនិធិផ្ទាល់សុទ្ធសរុបឡើយ ។

មុននឹងចេញរបាយការណ៍ពាក់ព័ន្ធ ធនាគារត្រូវពិនិត្យ ផ្ទៀងផ្ទាត់ ដើម្បីធានាការប្រតិបត្តិតាមកម្រិតកំណត់នេះ ។

ប្រសិនបើដើមទុនថ្នាក់ទីពីរលើសពីដើមទុនថ្នាក់ទីមួយ ធនាគារជាតិនៃកម្ពុជានឹងមានវិធានការសមស្រប។

ប្រការ ៥.

ដើមទុនថ្នាក់ទីមួយ ត្រូវគណនាដូចខាងក្រោម ៖

I- សរុបរង A: (ខ្ទង់ ត្រូវបូក)

- ដើមទុន ឬទាយជ្ជទាន ដែលបានបង់
- ទុនបម្រុងដែលមិនមែនជាទុនបម្រុងដែលត្រូវបានវាយតម្លៃឡើងវិញ
- បុព្វលាភទាក់ទងនឹងដើមទុន (បុព្វលាភភាគហ៊ុន)
- ប្រាក់ចំណេញរក្សាទុកត្រឹមកម្រិត ២០% នៃសរុបរង A ។ ចំនួនលើសពី ២០% នៃសរុបរង A ធនាគារអាចសម្រេចរក្សាទុកជាទុនបម្រុង
- ប្រាក់ចំណេញសុទ្ធដែលត្រូវបានធ្វើសវនកម្មរួចហើយ សម្រាប់ឆ្នាំហិរញ្ញវត្ថុចុងក្រោយ
- លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏អាចអនុម័តខ្ទង់ផ្សេងទៀត ដែលត្រូវបញ្ចូលទៅក្នុងសរុបរង A ដូចជាប្រាក់ចំណេញដែលបានកត់ត្រានៅក្នុងការិយបរិច្ឆេទ លុះត្រាតែ: ១-ប្រាក់ចំណេញនោះត្រូវបានកំណត់បន្ទាប់ពីដកចេញបន្ទុកចំណាយទាំងអស់នៅក្នុងរយៈពេលដូចគ្នា (ការរំលោះសំវិធានធន និងការកែតម្រូវតម្លៃសុទ្ធ) ២-ប្រាក់ចំណេញនោះត្រូវបានគណនាជាចំនួនសុទ្ធដោយដកចេញ

នូវចំនួនប្រាក់ពន្ធនិងភាគលាភដែលត្រូវសង ៣-ប្រាក់ចំណេញសុទ្ធនេះត្រូវបានបញ្ជាក់ពីសវនករឯករាជ្យ។

II- សរុបរង B: (ខ្ទង់ ត្រូវដក)

- ភាគហ៊ុនផ្ទាល់ដែលកាន់កាប់ដោយធនាគារ តាមតម្លៃសុទ្ធចុះបញ្ជី
- ការខាតបង្គរ
- ទ្រព្យសកម្មអរូបិយ៍ (ដូចជា តម្លៃកេរ្តិ៍ឈ្មោះ ... ជាដើម)
- ចំពោះភាគទុនិក គណៈនាយក និងភាគីសម្ព័ន្ធញ្ញាតិដូចមាននិយមន័យ នៅក្នុងច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ:
  - . ចំណែកដើមទុន ឬទាយជ្ជទាន ដែលមិនទាន់បានបង់
  - . ប្រាក់កម្ចី ឥណទានវិបារូបន៍ និងបុរេប្រទាន
  - . ឧបករណ៍បំណុលដែលកាន់កាប់ដោយធនាគារតាមតម្លៃសុទ្ធចុះបញ្ជី (Net Book Value) ហើយមានហត្ថលេខារបស់បុគ្គលពាក់ព័ន្ធទាំងនោះ
- ការខាតក្នុងគ្រាប្រតិបត្តិការ ក្រៅពីការខាតនាចុងការិយបរិច្ឆេទប្រចាំឆ្នាំដែលរួមទាំងរាល់សំវិធានធនលើបំណុលនិងមូលបត្រ មិនដំណើរការ ក៏ដូចជាការកែតម្រូវដទៃទៀតសម្រាប់ការរំលោះនៅក្នុងរយៈពេលដូចគ្នា ។ សំវិធានធននិងការរំលោះត្រូវស្របតាមបទបញ្ញាជាធរមាន ដោយផ្អែកលើការវាយតម្លៃដោយប្រុងប្រយ័ត្នលើហានិភ័យដែលពាក់ព័ន្ធ ។

ដើមទុនថ្នាក់ទីមួយ = សរុបរង A - សរុបរង B ។

ប្រការ ៦.

ដើមទុនថ្នាក់ទីពីរមិនត្រូវលើសពី ១០០% នៃដើមទុនថ្នាក់ទីមួយសម្រាប់គណនាមូលនិធិផ្ទាល់សុទ្ធសរុប។

ប្រសិនបើដើមទុនថ្នាក់ទីពីរលើសពីដើមទុនថ្នាក់ទីមួយ ដូចបានគណនាក្នុងប្រការ ៥ នៃប្រកាសនេះធនាគារមិនត្រូវយកចំនួនដែលលើសពី ១០០% នៃដើមទុនថ្នាក់ទីមួយនោះមកគណនាបញ្ចូលឡើយ ។

III- សរុបរង C: (ខ្ទង់ ត្រូវបូក)

- ការវាយតម្លៃទុនបម្រុងឡើងវិញដោយមានការយល់ព្រមជាមុន ជាលាយលក្ខណ៍អក្សរពីធនាគារជាតិនៃកម្ពុជា
- សំវិធានធនសម្រាប់ហានិភ័យទូទៅរបស់ធនាគារ ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- សំវិធានធនទូទៅ ១% ដែលបានកំណត់នៅក្នុង ប្រកាសស្តីពីការធ្វើចំណាត់ថ្នាក់ និងសំវិធានធនលើទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

- ឧបករណ៍បំណុលបន្ទាប់បន្សំមិនអាចលើសពី ៥០% នៃដើមទុនថ្នាក់ទីមួយ ហើយត្រូវបំពេញឲ្យបានគ្រប់លក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ខាងក្រោម
- ខ្ទង់ដទៃទៀតដែលមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីធនាគារជាតិនៃកម្ពុជា ។

IV- សរុបរង D: (ខ្ទង់ ត្រូវដក)

- ការចូលភាគកម្មតាមតម្លៃសុទ្ធចុះបញ្ជីនៅក្នុងគ្រឹះស្ថានធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ រួមទាំងក្រុមហ៊ុនមូលបត្រ
- ខ្ទង់ផ្សេងទៀត ដូចជាបន្ទុកចំណាយដែលត្រូវបង់។

ដើមទុនថ្នាក់ទីពីរ = សរុបរង C - សរុបរង D ។

ប្រការ ៧.

៧.១ បំណុលបន្ទាប់បន្សំត្រូវមានឯកសារទ្រទ្រង់ រួមទាំងកិច្ចសន្យាផងដែរ ។ កិច្ចសន្យានោះត្រូវមានបញ្ជាក់ច្បាស់ពីលំដាប់នៃម្ចាស់បំណុល (Subscriber) ដែលនៅខ្ពស់បន្ទាប់ពីភាគទុនិកធម្មតា កាលវសាន្ត និងលក្ខខណ្ឌផ្សេងទៀត។

៧.២ បំណុលបន្ទាប់បន្សំនេះអាចបញ្ចូលក្នុងដើមទុនថ្នាក់ទីពីរបានលុះត្រាតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីធនាគារជាតិនៃកម្ពុជា ។

៧.៣ ធនាគារមិនត្រូវសងបំណុលបន្ទាប់បន្សំឲ្យវិនិយោគិនវិញដោយមិនមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីធនាគារជាតិនៃកម្ពុជាឡើយ ។ ប្រសិនបើធនាគារសម្រេចចិត្តសងបំណុលបន្ទាប់បន្សំដោយគ្មានការអនុញ្ញាតជាមុន ឥណទាយកមិនមែនជាម្ចាស់បំណុលបន្ទាប់បន្សំរបស់ធនាគារ ឬអាជ្ញាធរត្រួតពិនិត្យធនាគារអាចជំទាស់នឹងសំណងបែបនេះ ។ ក្នុងករណីនេះ ម្ចាស់បំណុលដែលទទួលសំណងបំណុលបន្ទាប់បន្សំមិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងចំនួននោះត្រឡប់មកធនាគារវិញឡើយនៅពេលមានការតម្រូវ ។

៧.៤ ចំពោះឧបករណ៍បំណុលបន្ទាប់បន្សំ ដែលមានកំណត់កាលវសាន្តនៅពេលចុះកិច្ចសន្យា ធនាគារត្រូវអនុវត្តការសងរំលោះថេរប្រចាំឆ្នាំចំនួនមួយភាគប្រាំនៃបំណុលបន្ទាប់បន្សំ ចាប់ផ្តើមពីរយៈពេលប្រាំឆ្នាំមុនកាលវសាន្តនៃកិច្ចសន្យា ។ ការសងរំលោះបែបនេះត្រូវធ្វើឡើងតាមដំណាក់កាលដើម្បីឲ្យចំនួននៅក្នុងសរុបរង C ស្មើនឹងសូន្យនៅកាលវសាន្តនៃកិច្ចសន្យា ។

៧.៥ ចំពោះឧបករណ៍បំណុលបន្ទាប់បន្សំ ដែលពុំមានកំណត់កាលវសាន្តនៅពេលចុះកិច្ចសន្យា ធនាគារត្រូវជូនដំណឹងមកធនាគារជាតិនៃកម្ពុជា យ៉ាងហោចណាស់មុនប្រាំឆ្នាំ អំពីបំណងរបស់ខ្លួនក្នុងការសងបំណុលបន្ទាប់បន្សំទាំងនោះ ។ ប្រសិនបើធនាគារជាតិនៃកម្ពុជាមិនជំទាស់ចំពោះការសងរំលោះនេះទេ ធនាគារត្រូវអនុវត្តការសងរំលោះថេរប្រចាំឆ្នាំចំនួនមួយភាគប្រាំនៃបំណុលបន្ទាប់បន្សំ ចាប់ផ្តើមពីរយៈពេលប្រាំឆ្នាំមុនកាលបរិច្ឆេទដែលត្រូវបានកំណត់ដើម្បីសងរំលោះបំណុលទាំងស្រុង ។

៧.៦ ធនាគារជាតិនៃកម្ពុជាអាចនឹងសម្រេចផ្តល់ការអនុញ្ញាត ឬបដិសេធការសងរំលោះទាំងស្រុងនូវបំណុលបន្ទាប់បន្សំ ដោយផ្អែកលើស្ថានភាពហិរញ្ញវត្ថុជាទូទៅរបស់ធនាគារ ។

ប្រការ ៨.

ប្រកាសស្តីពីដើមទុនអប្បបរមារបស់ធនាគារពាណិជ្ជ លេខ ធ៧-០០-៣៩ប្រក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០ និង ប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ លេខ ធ៧-០០-៤៧ ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៩.

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១០.

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

ភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ២០១០

ទេសាភិបាល

ជា_ចាន់តូ

<u>កន្លែងទទួល</u>

- ដូចប្រការ ៩
  " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ

<u>ចម្លងជូន</u>

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជ្រាបជាព័ត៌មាន "
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7-10-182 Prokor

Unofficial Translation

PRAKAS
ON
THE CALCULATION OF BANKS' NET WORTH

The Governor of the National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27 of January 26, 1996 promulgating the Law on the Organization and Functioning of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1206/036 of December 29, 2006 promulgating the Law on the amendment of article 14 and 57 of Organization and Functioning of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999 promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/RKT/0508/526 of May 13, 2008 on the reappointment of **His Excellency Chea Chanto** as Governor General of the National Bank of Cambodia, equivalent to Senior Minister;
- Pursuant to the recommendation made by National Bank of Cambodia management during the date on 14 September 2010 meeting.

Decides:

Article 1:

Banks are required to calculate their "Net Worth" in compliance with the provisions set forth in this Prakas. All regulatory ratios and limits referring to "Net Worth" shall be calculated in full accordance with the calculation rules. In addition, paid-in capital or endowment shall be equal or superior to the applying minimum capital requirement.

Article 2.

Banks shall establish internal control policies, procedures and processes aimed at ensuring that they permanently comply with all the regulatory requirements related to minimum solvency ratio and to limitations referring to "Net Worth".

Article 3.

The NBC might impose the banks specific calculations, especially in the form of subtractions of additional items from their "Net Worth", notwithstanding the general calculation rules set forth in this Prakas. Such specific treatments aim at restoring compliance with all regulatory requirements and at reflecting actual or potential risk for prudential purposes.

Such specific treatments shall be notified in writing by the NBC and immediately implemented by banks until otherwise instructed, in writing as well.

Article 4.

The Total Net Worth consists of two separate components:

- Tier 1 capital (Core capital), and
- Tier 2 capital (Supplementary capital).

Tier 2 capital shall not exceed 100 % of Tier 1 capital or not more than 50 % of total net worth.

Prior to issuing their regulatory reports, bank shall implement checks and controls aimed at ensuring compliance with this limit.

Should Tier 2 capital exceed Tier 1 capital, the NBC shall take any appropriate actions.

Article 5.

Tier 1 capital shall be calculated as follows:

I. **Sub-total A : (Items to be added)**

- Paid-in capital or endowment
- Reserves, other than revaluation reserves
- Premiums related to capital (share premiums)
- Retained earnings, up to 20 % of Sub-Total A. Above 20 % of Sub-total A, banks shall consider making a decision about reserving the corresponding amount

- Audited net profit for the last financial year.
- In addition, the NBC might approve other items to be included into Sub-total A, such as profits as recorded on intermediate dates, provided that 1°) such profits be determined after posting all the charges related to the corresponding period (allowances for depreciations, provisions and net value adjustments), 2°) such profits be calculated net of foreseeable taxes and dividends, and 3°) such net profits have been certified by the external auditors.

II. Sub-total B : (Items to be subtracted)

- Own shares held by bank at their net book value
- Accumulated losses
- Intangible assets (such as goodwill ... etc.)
- For shareholders, directors and any other related party according to the definition established in the Law on Banking and Financial Institutions:
  - Unpaid portion of capital;
  - Loans, overdrafts and other advances;
  - Debt instruments held by the bank and bearing the signature of the persons concerned, at their net book value;
- Losses determined on dates other than regular year-ends, including all the provisions for non performing debts and securities as well as any other value adjustments for depreciations in the corresponding period of time. Provisioning and depreciations shall be performed in compliance with the regulations based on prudent appraisals of risks involved.

Tier 1 capital = Sub-total A - Sub-total B

Article 6.

Tier 2 Capital shall not exceed 100 % of Tier 1 Capital for the calculation of Total Net Worth.

Should Tier 2 Capital exceed Tier 1 Capital as calculated in Article 5 of this Prakas, banks shall not take the amount exceeding 100 % of Tier 1 Capital to include in Total Net Worth calculation.

III. Sub-total C : (Items to be added)

- Reevaluation reserves with the prior approval, in writing, from the NBC;
- Provisions for general banking risks with the prior agreement of the NBC

- General provision of 1% foreseen in Prakas on Asset Classification and Provisioning in Banking and Financial Institutions
- Subordinated debt instruments, which shall not exceed 50% of Tier 1 Capital, provided that they fulfill all the conditions set forth in Article 7 below;
- Other items with the prior approval of the NBC in writing.

IV. **Sub-total D : (Items to be subtracted)**

- Equity participation(s) in banking or financial institutions, including securities companies, at their net book value
- Other items, such as deferred charges.

Tier 2 Capital = Sub-total C - Sub-total D

Article 7.

7.1- Subordinated Debt shall have supported documents including contracts as well. Such contracts shall clearly specify the subordination of subscribers, with a ranking just above regular shareholders, maturity and other conditions.

7.2- The subordinated debt shall be included into Tier 2 capital after obtaining prior approval in writing from the National Bank of Cambodia.

7.3- Bank shall not reimburse subordinated Debt to investors before obtaining prior approval in writing from the NBC. Should a bank decide to reimburse such subordinated debt without the prior approval, such reimbursement could be opposed either by the bank's non-subordinated creditors or by the Banking Supervisory Authority. In this case, the reimbursed subordinated debt holders cannot consider themselves as freed of their liability under such circumstances and could be required to return the funds to the bank.

7.4- For subordinated debt instruments issued with a contractual maturity at the origin in the issuance and subscription contract, banks are required to amortize the corresponding subordinated debt by one fifth ($1/5^{th}$) starting over the five years preceding the contractual maturity. Such amortizations shall be performed in a cumulative manner time going so that the amount accounted for under Sub-total C equals zero at contractual maturity.

7.5- For subordinated debt instruments issued for an undefined period of time, the bank shall inform the NBC at least five years before of its intentions to reimburse such subordinated debt. Provided that the NBC does not object to such reimbursement, the bank shall amortize the corresponding subordinated debt by one

fifth (1/5th) starting over the five years preceding the date for effective reimbursement.

7.6- The NBC shall approve or object of effective reimbursement of subordinated debt in light of the bank's overall financial condition.

Article 8.

The Prakas on Commercial Bank' Minimum Capital N° B7-00-39 Pro Kor dated on February 09, 2000 and the Prakas on the Calculation of Banks' Net Worth N° B7-00-47 Pro Kor dated on February 16, 2000 shall be repealed.

Article 9.

The General Directorate, the General Secretariat, the General Inspection, the General Cashier, and all Banking and Financial Institutions under the NBC's supervisory authority shall strictly implement this Prakas.

Article 10.

The present Prakas shall take effect from this signing date.
